# ផែនការរៀបចំដែនដីខេត្តបាត់ដំបង

## ចក្ខុវិស័យឆ្នាំ២០៣០

ក្រសួង.ដ.ន.ស.
ចូល
លេខ 1532
ថ្ងៃទី 20.6.18
បញ្ជូន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៨០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តបាត់ដំបង

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

## សម្រេច

**មាត្រា ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តបាត់ដំបង ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣០ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ។

**មាត្រា ២.-**

ផែនការរៀបចំដែនដីខេត្តបាត់ដំបងអាចធ្វើការកែសម្រួលក្នុងរយៈពេល ៥ (ប្រាំ)ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលផែនការរៀបចំដែនដីខេត្តបាត់ដំបងមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលផែនការរៀបចំដែនដីខេត្តបាត់ដំបង ត្រូវអនុវត្តតាមនីតិវិធីនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ពុធ ១ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់**

**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ការដាក់ឱ្យអនុវត្តផែនការរៀបចំដែនដីខេត្តបាត់ដំបង ចក្ខុវិស័យឆ្នាំ២០៣០

ដោយអនុក្រឹត្យលេខ...៨០ អនក្រ.បក ចុះថ្ងៃ ព្រ.៦ កើត ខែមិគសិរ សំរឹទ្ធិស័ក ព.ស.២៥៦២

ត្រូវនឹងថ្ងៃទី...១៣... ខែ...ធ្នូ... ឆ្នាំ២០១៨

# ផែនការរៀបចំដែនដីខេត្តបាត់ដំបង

## ចក្ខុវិស័យឆ្នាំ២០៣០

## មាតិកា

ទំព័រ


**១- សេចក្តីផ្តើម** ........................................ ១

**២- ចក្ខុវិស័យ** ........................................ ២

២.១- ក្របខណ្ឌសេដ្ឋកិច្ច សង្គម ........................................ ២

២.២- ចក្ខុវិស័យ ........................................ ២

**៣- គោលបំណងនិងគោលដៅ** ........................................ ៣

៣.១- គោលបំណង ........................................ ៣

៣.២- គោលដៅ ........................................ ៣

**៤- យុទ្ធសាស្ត្រគម្រប់និងអភិវឌ្ឍន៍** ........................................ ៤

៤.១- អ័ក្សជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ ........................................ ៤

៤.២- អ័ក្សជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍក្នុងក្របខណ្ឌជាតិ ........................................ ៤

៤.៣- យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្នុងក្របខណ្ឌខេត្ត ........................................ ៤

៤.៣.១- ការអភិវឌ្ឍនគរូបនីយកម្មនិងលំនៅឋាន ........................................ ៤

៤.៣.២- ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន ........................................ ៥

៤.៣.៣- ការគ្រប់គ្រងទីជម្រាល ........................................ ៦

៤.៣.៤- ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រនិងកសិកម្ម ........................................ ៧

៤.៣.៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសនិងឧស្សាហកម្ម ........................................ ៨

៤.៣.៦- ការអភិវឌ្ឍទេសចរណ៍ ........................................ ៩

**៥- ផែនការសកម្មភាព** ........................................ ៩

៥.១- គម្រោងអាទិភាពក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ ........................................ ៩

៥.២- គម្រោងអាទិភាពក្នុងក្របខណ្ឌជាតិ ........................................ ១០

៥.៣- គម្រោងអាទិភាពក្នុងក្របខណ្ឌខេត្ត ........................................ ១០

៥.៣.១- ការអភិវឌ្ឍនគរូបនីយកម្មនិងលំនៅឋាន ........................................ ១០

៥.៣.២- ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន ........................................ ១១

៥.៣.៣- ការគ្រប់គ្រងទីជម្រាលប្រកបដោយចីរភាព ........................................ ១២

៥.៣.៤- ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រនិងកសិកម្ម ........................................ ១៣

៥.៣.៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសនិងឧស្សាហកម្ម.............................. ១៣

៥.៣.៦- ការអភិវឌ្ឍទេសចរណ៍.......................................................................... ១៤

៥.៤- ការផ្សព្វផ្សាយ.......................................................................................... ១៥

**៦- ធនធានហិរញ្ញវត្ថុ**.......................................................................................... ១៥

**៧- ការត្រួតពិនិត្យនិងវាយតម្លៃ**.......................................................................... ១៥

៧.១- យន្តការ................................................................................................... ១៥

៧.២- ក្របខណ្ឌច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត .............................. ១៦

៧.៣- គោលការណ៍ នីតិវិធី និងភារកិច្ច.......................................................... ១៦

**៨- សេចក្តីសន្និដ្ឋាន** ............................................................................................ ១៧

**សន្ទានុក្រម**.......................................................................................................... ១៨

**ឯកសារឧបសម្ព័ន្ធ**.............................................................................................. ១៩

## ១-សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ស្ថិរភាពនិងវឌ្ឍនភាពសង្គម សេដ្ឋកិច្ចកម្ពុជា ជាកាលានុវត្តភាពជំរុញឱ្យមាននូវនិន្នាការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន ការប្រើប្រាស់ដីធ្លី លំនៅឋាន នគរូបនីយកម្ម និងតម្រូវការក្នុងការបង្កើតទីក្រុងតូចធំគ្រប់កម្រិត ដែលមាននូវបណ្តាញហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដូចជាសេវាកម្មនិងបច្ចេកទេសថាមពលនិងអគ្គិសនី សុខភាពនិងទឹកស្អាត អេកូឡូស៊ីនិងធនធានធម្មជាតិ ការគ្រប់គ្រងកាកសំណល់រឹងរាវ ការគ្រប់គ្រងគ្រោះមហន្តរាយ។ល។ ដើម្បីឆ្លើយតបទៅនឹងការវិវត្តទាំងនេះ ចាំបាច់ត្រូវមានការគិតគូរនិងកសាងឡើងនូវផែនការរៀបចំដែនដីនិងនគរូបនីយកម្ម ប្លង់គោលប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម ប្រកបដោយប្រសិទ្ធភាព សម្រាប់ធ្វើការគ្រប់គ្រងនិងការតម្រង់ទិសការអភិវឌ្ឍលើគ្រប់វិស័យឱ្យមានដំណើរប្រកបដោយចីរភាព និងធានាបាននូវការគ្រប់គ្រងដីកសិកម្ម ព្រៃឈើ ប្រព័ន្ធអេកូឡូស៊ី ការការពារបរិស្ថាន និងធនធានធម្មជាតិ។

ផែនការរៀបចំដែនដីខេត្តបាត់ដំបង ត្រូវបានរៀបចំនិងកសាងឡើងនៅឆ្នាំ២០០៥ ស្របតាមតម្រូវការការវិវត្តជាក់ស្តែងនៃស្ថានភាពសង្គម សេដ្ឋកិច្ច និងបរិស្ថាន ដោយផ្អែកលើកត្តាទីតាំងភូមិសាស្ត្រជាតំបន់ស្នូលភាគពាយ័ព្យនៃប្រទេសកម្ពុជា កត្តាធនធានធម្មជាតិនិងបរិស្ថាន កត្តាប្រវត្តិសាស្ត្រនិងបេតិកភណ្ឌវប្បធម៌ និងស្របតាមក្របខណ្ឌយុទ្ធសាស្ត្រ គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

សំខាន់ៗមានជាអាទិ៍ យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន។ល។

**២-ចក្ខុវិស័យ**

### ២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម

ផែនការរៀបចំដែនដីខេត្តបាត់ដំបង ត្រូវបានរៀបចំឡើងដោយបានសិក្សាប្រមូលនិងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គម ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិ សមស្របតាមអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយដីធ្លី "សៀវភៅ ស ដីធ្លី"។

ដើម្បីកំណត់ចក្ខុវិស័យនៃផែនការរៀបចំដែនដីខេត្តបាត់ដំបងដល់ឆ្នាំ២០៣០ ក្របខណ្ឌសេដ្ឋកិច្ចសង្គម ត្រូវបានសិក្សាវិភាគតាមបែបវិទ្យាសាស្ត្រ ដោយផ្អែកតាមរបាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ តាមរយៈការសិក្សាខាងលើនេះ ខេត្តបាត់ដំបងដែលមានផ្ទៃដី ១១ ៧៤៨ គីឡូម៉ែត្រក្រឡា ចំនួនប្រជាជននៅឆ្នាំ២០០៨ មានចំនួន ១ ០២៥ ១៧៤ នាក់ នៅឆ្នាំ២០១៨ មានចំនួន ១ ២៨៣ ២២៣ នាក់ ហើយនៅឆ្នាំ២០៣០ នឹងកើនដល់ ១ ៥១៩ ១៨៥ នាក់។ ចំពោះការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ខេត្តបាត់ដំបង គឺនៅឆ្នាំ២០០៨ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មមានចំនួន ៦៧០ ០៧៣ នាក់ (៧៦,៦៧%) ក្នុងវិស័យឧស្សាហកម្មមានចំនួន ៤៣ ៥២៤ នាក់ (៤,៩៨%) និងក្នុងវិស័យសេវាកម្មមានចំនួន ១៦០ ៣៧៣ នាក់ (១៨,៣៥%) ហើយនៅឆ្នាំ២០៣០ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មនឹងមានការកើនឡើងដល់ចំនួន ៨០៦ ២៦៣ នាក់ (៦០%) ក្នុងវិស័យឧស្សាហកម្មកើនឡើងដល់ចំនួន ៨០ ៦២៦ នាក់ (៦ %) និងក្នុងវិស័យសេវាកម្មកើនដល់ចំនួន ៤៥៦ ៨៨៣ នាក់ (៣៤%)។

### ២.២-ចក្ខុវិស័យ

ផែនការរៀបចំដែនដីខេត្តបាត់ដំបងចក្ខុវិស័យឆ្នាំ២០៣០ គឺសំដៅរៀបចំ និងអភិវឌ្ឍ *"ខេត្តបាត់ដំបងជាតំបន់ស្នូលសេដ្ឋកិច្ចភាគពាយ័ព្យនៃប្រទេសកម្ពុជា"* តាមរយៈការជំរុញរៀបចំនិងអភិវឌ្ឍជា៖

– តំបន់ស្នូលនគរូបនីយកម្ម អភិបាលកិច្ចល្អ និងការអភិវឌ្ឍធនធានមនុស្សកាន់តែប្រសើរឡើង

- តំបន់ផលិតផលកសិកម្មប្រកបដោយគុណភាពខ្ពស់
- មជ្ឈមណ្ឌលពាណិជ្ជកម្មនិងឧស្សាហកម្មកែច្នៃផលិតផលកសិកម្មប្រកបដោយការប្រកួតប្រជែង
- តំបន់ទេសចរណ៍ធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រ
- តំបន់សមាហរណកម្មចម្រុះរវាងវិស័យសេដ្ឋកិច្ច សង្គម វប្បធម៌ និងធនធានធម្មជាតិ។

## ៣-គោលបំណងនិងគោលដៅ

### ៣.១-គោលបំណង

ផែនការរៀបចំដែនដីខេត្តបាត់ដំបង មានគោលបំណងជាអាទិ៍៖

- ការគ្រប់គ្រងនិងតម្រង់ទិសការអភិវឌ្ឍនិងអភិរក្សលើផ្ទៃក្រឡាបវត្តសង្គម សេដ្ឋកិច្ច និងបរិស្ថាន
- តួនាទីជាស្នូលនៃអ័ក្សអភិវឌ្ឍស្ថិតក្នុងក្របខណ្ឌជាតិ ក្របខណ្ឌតំបន់ និងក្របខណ្ឌអន្តរជាតិ ដូចជាអាស៊ាន និងមហាអនុតំបន់ទន្លេមេគង្គ
- ការគ្រប់គ្រង បែងចែក និងប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាពនិងចីរភាព សម្រាប់ការអភិវឌ្ឍ និងអភិរក្សលើគ្រប់វិស័យប្រកបដោយតុល្យភាពនិងសមាហរណកម្មចម្រុះ
- បង្កើនផលិតផលកសិកម្មនិងឧស្សាហកម្មកែច្នៃកសិផលទាំងបរិមាណនិងគុណភាព សម្រាប់បំពេញតម្រូវការក្នុងប្រទេសនិងការនាំចេញ
- ពង្រឹងនិងពង្រីកសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងទំនាក់ទំនងវប្បធម៌ក្នុងតំបន់ស្នូលជាយុទ្ធសាស្ត្រជួរមុខ នៅតាមបណ្ដោយព្រំដែន។

### ៣.២-គោលដៅ

ផែនការរៀបចំដែនដីខេត្តបាត់ដំបង មានគោលដៅកំណត់៖

- តំបន់នគរូបនីយកម្មកម្រិតខ្ពស់ កម្រិតមធ្យម និងកម្រិតទាប ឱ្យកាន់តែប្រសើរឡើងសម្រាប់ការរស់នៅ ឱកាសការងារ ការធ្វើពាណិជ្ជកម្ម និងការអភិវឌ្ឍទេសចរណ៍
- តំបន់កសិកម្មមានបរិមាណនិងគុណភាពខ្ពស់ ជាពិសេសដំណាំស្រូវ និងដំណាំចម្ការ
- តំបន់ឧស្សាហកម្មកែច្នៃកសិផល ដោយចុះបញ្ជីផ្លាកសម្គាល់ភូមិសាស្ត្រទំនិញ "ផលិតផលខេត្តបាត់ដំបង" ប្រកបដោយគុណភាពប្រកួតប្រជែង
- តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ វប្បធម៌ និងធនធានធម្មជាតិប្រកបដោយចីរភាព មានចំនួន ៣៩ ទីតាំង។

## ៤-យុទ្ធសាស្ត្រគម្រង់ទិសអភិវឌ្ឍន៍

### ៤.១-អ័ក្សជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ

ខេត្តបាត់ដំបងមានអ័ក្សជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍក្នុងក្របខណ្ឌតំបន់និងអន្តរជាតិសំខាន់ៗ ចំនួនពីរគឺ៖

ក)- ក្របខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីផែនការធ្វើសហប្រតិបត្តិការសេដ្ឋកិច្ចកម្ពុជា-ថៃ សម្រាប់រយៈពេលខ្លី មធ្យម និងវែង លើវិស័យពាណិជ្ជកម្ម ការវិនិយោគ ផលិតផលកែច្នៃ ទេសចរណ៍ និងសេវាកម្មផ្សេងៗ។

ខ)- យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដីដែលខេត្តបាត់ដំបងដើរតួនាទីជា "មជ្ឈមណ្ឌលកំណើនអនុតំបន់"នៃអ័ក្សអភិវឌ្ឍន៍សេដ្ឋកិច្ចខាងត្បូង "បាងកក-ភ្នំពេញ-ហូជីមិញ" នៃមហាអនុតំបន់ទន្លេមេគង្គ ដែលមានបណ្តាញផ្លូវអាស៊ានឆ្លងកាត់។

### ៤.២-អ័ក្សជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍក្នុងក្របខណ្ឌជាតិ

ក្នុងក្របខណ្ឌជាតិ ខេត្តបាត់ដំបងមានទីតាំងភូមិសាស្ត្រប្រកបដោយភាពអំណោយផល និងជាតំបន់ស្នូលភាគពាយ័ព្យនៃប្រទេស ដែលមានអ័ក្សភ្ជាប់តំបន់សំខាន់ៗជុំវិញ រួមមាន៖

ក)- អ័ក្ស "ភ្នំពេញ-បាត់ដំបង-ប៉ោយប៉ែត" តាមបណ្តោយផ្លូវជាតិលេខ៥ គឺជាអ័ក្សដឹកជញ្ជូនដ៏សំខាន់នូវបណ្តាភស្តុភារ ផលិតផលកសិកម្ម និងឧស្សាហកម្មកែច្នៃកសិផលទៅកាន់តំបន់កណ្តាលនៃប្រទេស និងបណ្តាខេត្តដទៃទៀត។

ខ)- អ័ក្សនៃតំបន់ជាប់បឹងទន្លេសាប មានខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ គឺជាតំបន់ដែលមានសក្តានុពលធំធេងលើផ្នែកកសិកម្ម ជលផល ព្រៃលិចទឹក និងទេសចរណ៍បែបធម្មជាតិ។

គ)- អ័ក្សនៃតំបន់ឆ្នេរភ្ជាប់ពីប្រទេសថៃ ឆ្លងកាត់តាមខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប ឆ្ពោះទៅប្រទេសវៀតណាម គឺជាតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច ឧស្សាហកម្ម ភស្តុភារ និងទេសចរណ៍កម្រិតអន្តរជាតិ។

ឃ)- អ័ក្សនៃតំបន់ស្នូលជាយុទ្ធសាស្ត្រជួរមុខនៅតាមបណ្តោយព្រំដែនដីគោកកម្ពុជា-ថៃ រួមមានខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ គឺជាតំបន់ដែលមានសក្តានុពលអភិវឌ្ឍន៍សេដ្ឋកិច្ចជាមួយប្រទេសថៃ។

### ៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្នុងក្របខណ្ឌខេត្ត

#### ៤.៣.១-ការអភិវឌ្ឍនគរូបនីយកម្មនិងលំនៅឋាន

ក)- ការកំណត់រចនាសម្ព័ន្ធស្នូលអភិវឌ្ឍន៍នគរូបនីយកម្ម

កំណត់និងបែងចែកតំបន់ស្នូលអភិវឌ្ឍនិងអ័ក្សនៃការអភិវឌ្ឍជាបីកម្រិត តាមលក្ខណៈនិងមុខងារនគរូបនីយកម្ម ដូចខាងក្រោម៖

- តំបន់នគរូបនីយកម្មកម្រិតខ្ពស់ គឺក្រុងបាត់ដំបងជា "មជ្ឈមណ្ឌលមេ"
- តំបន់នគរូបនីយកម្មកម្រិតមធ្យម គឺទីប្រជុំជនស្រុកចំនួន៦ ជា "មជ្ឈមណ្ឌលរង" រួមមានទីប្រជុំជនស្រុកមោងឬស្សី ស្រុករតនមណ្ឌល ស្រុកថ្មគោល ស្រុកបវេល ស្រុកកំរៀង និងស្រុកសំពៅលូន
- តំបន់នគរូបនីយកម្មកម្រិតទាប គឺទីប្រជុំជនស្រុកចំនួន៧ ជា"អនុមជ្ឈមណ្ឌលរង" រួមមានទីប្រជុំជនស្រុកឯកភ្នំ ស្រុកសង្កែ ស្រុករុក្ខគិរី ស្រុកគាស់ក្រឡ ស្រុកបាណន់ ស្រុកសំឡូត និងស្រុកភ្នំព្រឹក។

ខ)- ការអភិវឌ្ឍលំនៅឋាន

ការសាងសង់លំនៅឋានថ្មីដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជន និងតម្រូវការនៃការអភិវឌ្ឍ ត្រូវធ្វើឡើងក្នុងតំបន់មួយចំនួន ដូចខាងក្រោម៖

- តំបន់លំនៅឋានក្នុងក្រុងនិងទីប្រជុំជន
- តំបន់សេដ្ឋកិច្ចពិសេស តំបន់អភិវឌ្ឍន៍សមាហរណកម្មចម្រុះ និងតំបន់ស្នូលជាយុទ្ធសាស្ត្រជួរមុខនៅតាមបណ្តោយព្រំដែន
- តំបន់លំនៅឋានថ្មីក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច។

### ៤.៣.២-ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន

ប្រព័ន្ធដឹកជញ្ជូនដែលត្រូវធ្វើការអភិវឌ្ឍថ្មី ជួសជុល ឬកែលម្អ ដើម្បីបង្កើនសមត្ថភាពបម្រើដល់សកម្មភាពដឹកជញ្ជូនចេញចូល ឬឆ្លងកាត់ខេត្ត រួមមាន៖

ក)- បណ្តាញផ្លូវថ្នល់

- បណ្តាញផ្លូវថ្នល់ សម្រាប់តភ្ជាប់ពីស្នូលអភិវឌ្ឍមួយទៅស្នូលអភិវឌ្ឍមួយទៀត គឺពីតំបន់នគរូបនីយកម្មកម្រិតខ្ពស់ ទៅតំបន់នគរូបនីយកម្មកម្រិតមធ្យម និងទៅតំបន់នគរូបនីយកម្មកម្រិតទាប
- បណ្តាញផ្លូវថ្នល់នៅផ្នែកខាងជើងនិងបណ្តាញផ្លូវថ្នល់នៅផ្នែកខាងត្បូង ដើម្បីធានាការដឹកជញ្ជូនក្នុងខេត្តនិងឆ្លងកាត់ខេត្ត
- បណ្តាញផ្លូវថ្នល់នៅផ្នែកខាងជើង គឺសម្រាប់តភ្ជាប់រវាងស្រុកថ្មគោលនិងស្រុកបវេល ដែលជាមជ្ឈមណ្ឌលផ្គត់ផ្គង់ និងបង្កើនសកម្មភាពសេដ្ឋកិច្ចដល់តំបន់នៅតាមព្រំដែន ដូចជាស្រុកកំរៀង ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន

- បណ្តាញផ្លូវថ្នល់នៅផ្នែកខាងត្បូង គឺសម្រាប់តភ្ជាប់រវាងក្រុងបាត់ដំបង ស្រុករតនមណ្ឌលនិងស្រុកសំឡូត និងរវាងក្រុងបាត់ដំបង ស្រុកមោងឫស្សី និងស្រុកគាស់ក្រឡ ព្រមទាំងសម្រាប់តភ្ជាប់រវាងស្រុកសំឡូតនិងស្រុកគាស់ក្រឡ។

ខ)- បណ្តាញផ្លូវអយស្ម័យយាននិងស្ថានីយរថភ្លើង

- បណ្តាញផ្លូវអយស្ម័យយានភ្នំពេញ-ក្រុងបាត់ដំបង-ក្រុងប៉ោយប៉ែត
- ស្ថានីយរថភ្លើងក្រុងបាត់ដំបង។

គ)- បណ្តាញផ្លូវទឹកនិងកំពង់ផែ

- តាមផ្លូវទឹកនៃស្ទឹងសង្កែ ដែលជាបណ្តាញផ្លូវទឹកសំខាន់នៅក្នុងខេត្តនិងតភ្ជាប់ទៅបឹងទន្លេសាប
- កំពង់ផែទី១ស្ថិតនៅក្នុងក្រុងបាត់ដំបង ប្រើប្រាស់សម្រាប់អ្នកទេសចរធ្វើដំណើរទៅមកក្នុងខេត្តបាត់ដំបងនិងទៅកាន់ខេត្តសៀមរាប
- កំពង់ផែទី២ស្ថិតនៅទល់មុខផ្សារឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ ប្រើប្រាស់សម្រាប់ការដឹកជញ្ជូនទំនិញផ្សេងៗនិងការចូលចតរបស់កាណូតធំៗនៅរដូវវស្សា។

ឃ)- បណ្តាញផ្លូវអាកាស

- អាកាសយានដ្ឋានបច្ចុប្បន្ន មានទីតាំងនៅក្នុងក្រុងបាត់ដំបង តាមបណ្តោយផ្លូវជាតិលេខ ៥ អាចបង្កនូវការរំខាននិងហានិភ័យផ្សេងៗដល់តំបន់ពាណិជ្ជកម្មនិងលំនៅឋានដែលនៅជុំវិញ ដូចនេះទីតាំងថ្មីសម្រាប់សាងសង់ព្រលានយន្តហោះ គួរត្រូវបានកំណត់ដើម្បីត្រៀមលក្ខណៈសម្រាប់ការអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវអាកាសក្នុងពេលអនាគត។

### ៤.៣.៣- ការគ្រប់គ្រងទីជម្រាល

យុទ្ធសាស្ត្រគ្រប់គ្រងទីជម្រាលឱ្យមានចីរភាព តុល្យភាព និងនិរន្តរភាពធារាសាស្ត្រ ដើម្បីកាត់បន្ថយការហូរច្រោះ ឬគោករាក់នៅបាតខ្សែទឹកធម្មជាតិ ការប៉ះពាល់ដល់បរិមាណនិងគុណភាពទឹក និងធនធានធម្មជាតិ គឺ៖

ក)- កំណត់តំបន់ដីព្រៃគ្រប់ប្រភេទ និងធ្វើចំណាត់ថ្នាក់ដីព្រៃ ដូចជាដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ តំបន់ការពារ និងដីព្រៃឯកជន។

ខ)- កំណត់តំបន់ការពារព្រំប្រទល់ និងដែនប្រតិបត្តិការឱ្យបានច្បាស់លាស់ ដូចជាតំបន់ស្នូល (ព្រែកទាល់) តំបន់អភិរក្ស តំបន់ប្រើប្រាស់ប្រកបដោយចីរភាព និងតំបន់សហគមន៍។

គ)- តំបន់សហគមន៍ព្រៃឈើ តាមរយៈការចុះកិច្ចព្រមព្រៀងជាមួយសហគមន៍ព្រៃឈើដែលបានកំណត់រួច មានចំនួន៩១ទីតាំង និងការកំណត់តំបន់សហគមន៍ព្រៃឈើថ្មីបន្ថែមទៀតចំនួន៣៣ទីតាំង។

ឃ)- តំបន់វាលទំនាបជាប់បឹងទន្លេសាប តាមរយៈការគ្រប់គ្រងការប្រើប្រាស់ដីក្នុងតំបន់នីមួយៗ និងការគ្រប់គ្រងសហគមន៍នេសាទ ដែលបានកំណត់រួចមានចំនួន១២ទីតាំង តាមរយៈការចុះកិច្ចព្រមព្រៀងជាមួយសហគមន៍ទាំងនោះ។

ង)- ទីជម្រាលជាប់ខ្សែទឹកធម្មជាតិ តាមរយៈការគ្រប់គ្រងលើការប្រើប្រាស់ដីកសិកម្មនៅតាមតំបន់ជាប់ផ្លូវទឹកធម្មជាតិ មានបឹងទន្លេសាប ស្ទឹង ព្រែក អូរ បឹង។ល។ ដែលអាចបណ្តាលឱ្យមានការសឹករេចរឹលដី ការហូរច្រោះដីឬបាត់បង់គុណភាពដី និងការគ្រប់គ្រងលើការប្រើប្រាស់ជាតិគីមីពុលឬផលិតផលគ្រោះថ្នាក់ផ្សេងទៀត ដែលអាចប៉ះពាល់ដល់គុណភាពទឹក សុខភាពមនុស្ស និងសត្វ។

### ៤.៣.៤-ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រនិងកសិកម្ម

ប្រព័ន្ធធារាសាស្ត្រនិងកសិកម្ម ដែលត្រូវគ្រប់គ្រងនិងអភិវឌ្ឍដើម្បីបង្កើនសមត្ថភាពផលិតប្រកបដោយគុណភាពនិងបរិមាណគ្រប់គ្រាន់នៅគ្រប់តំបន់ និងគ្រប់រដូវកាល គឺៈ

ក)- ប្រព័ន្ធប្រឡាយមេសំខាន់ៗចំនួន៦កន្លែង មានប្រព័ន្ធធារាសាស្ត្រស្ទឹងបរវេល ប្រព័ន្ធធារាសាស្ត្រស្ទឹងមោងឬស្សី ប្រព័ន្ធធារាសាស្ត្រអាងទឹកកំពីងពួយ ប្រព័ន្ធធារាសាស្ត្រអាងទឹកសាលាតាអន ប្រព័ន្ធធារាសាស្ត្រទំនប់កង្ហត និងប្រព័ន្ធធារាសាស្ត្រអាងទឹកមានល័ក្ខ ដែលមានសក្តានុពលគ្របដណ្តប់ដល់តំបន់ផលិតកម្មស្រូវនៅទូទាំងខេត្ត។

ខ)- ជំរុញការអភិវឌ្ឍកសាងអាងទឹកថ្មីសំខាន់ៗចំនួន៣កន្លែង មានអាងទឹកស្ទឹងកុយ អាងទឹកស្ទឹងដូនទ្រី និងអាងទឹកស្ទឹងក្រញូង។

គ)- តំបន់ខ្ពង់រាបនៃខេត្តមានសក្តានុពលសម្រាប់ដំណាំកសិ-ឧស្សាហកម្ម សម្រាប់ការអភិវឌ្ឍរយៈពេលវែងៈ ការការពារប្រព័ន្ធជីវៈចម្រុះរបស់ដី និងការកែលម្អគុណភាពធនធានដីឡើងវិញទាំងផ្នែកគីមីសាស្ត្រ ទាំងផ្នែករូបសាស្ត្រ តាមរយៈការប្រើប្រាស់បច្ចេកទេសវិស្វកម្មទំនើបដើម្បីគ្រប់គ្រងសណ្ឋានដីនិងចរន្តទឹកហូរ។

ឃ)- ការកែច្នៃផលិតផលកសិកម្មចម្រុះនៅតាមតំបន់និងការកែលម្អចង្វាក់ផលិតកម្មកសិកម្មមូលដ្ឋានទាំងបរិមាណ ទាំងគុណភាព និងត្រូវលើកកម្ពស់ការផ្សព្វផ្សាយទីផ្សារសម្រាប់ផលិតផលក្នុងស្រុកដោយចុះបញ្ជីផ្លាកសម្គាល់ភូមិសាស្ត្រទំនិញ"ផលិតផលខេត្តបាត់ដំបង"។

ង)- ស្រុករតនមណ្ឌលនិងស្រុកបាណន់ ដែលជាតំបន់មានស្រទាប់ដីរាក់និងគ្មានអំណោយផលដល់ការធ្វើកសិកម្ម ត្រូវធ្វើការអភិវឌ្ឍការចិញ្ចឹមសត្វពាហនៈ។

ច)- ស្រុកបវេល ស្រុកថ្មគោល ស្រុកមោងឫស្សី និងស្រុកសង្កែ ដែលជាតំបន់មានផលិតផលស្រូវខ្ពស់ ត្រូវធ្វើការអភិវឌ្ឍចិញ្ចឹមសត្វជ្រូក។

ឆ)- ស្រុកគាស់ក្រឡ ស្រុកសំឡូត និងស្រុកមោងឫស្សី ដែលជាតំបន់មានអំណោយផលសម្រាប់ការចិញ្ចឹមសត្វ ពិសេសគោ ក្របី។

## ៤.៣.៥-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសនិងឧស្សាហកម្ម

បណ្តាញហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសនិងឧស្សាហកម្មសំខាន់ៗ ដែលត្រូវធ្វើការអភិវឌ្ឍកែលម្អ និងពង្រីកបន្ថែមគឺ៖

ក)- ប្រភពថាមពលនិងបណ្តាញចែកចាយអគ្គិសនីនៅក្នុងខេត្តបាត់ដំបង

- ខ្សែបញ្ជូនអគ្គិសនីមកពីទិសខាងជើង
- ខ្សែបញ្ជូនអគ្គិសនីភ្លោះមកពីទិសខាងត្បូង
- ទំនប់វារីអគ្គិសនីបាត់ដំបង១ មានកម្លាំងទំហំ ២៤ មេហ្គាវ៉ាត់ (កំពុងសិក្សា)
- ទំនប់វារីអគ្គិសនីបាត់ដំបង២ មានកម្លាំងទំហំ ៣៦ មេហ្គាវ៉ាត់ (កំពុងសិក្សា)
- ទំនប់វារីអគ្គិសនីបាត់ដំបង៣ មានកម្លាំងទំហំ ១៣ មេហ្គាវ៉ាត់ (កំពុងដាក់ឱ្យដំណើរការ)។

ខ)- ប្រព័ន្ធបណ្តាញទឹកស្អាតនិងអនាម័យ

- ប្រព័ន្ធបណ្តាញមេ បណ្តាញចែកចាយទឹកស្អាត ស្ថានីយនិងរោងចក្រផលិតទឹកស្អាតនៅតាមបណ្តាក្រុង និងទីប្រជុំជនស្រុកទាំង១៣
- ប្រព័ន្ធបណ្តាញផលិតនិងចែកចាយទឹកស្អាតដទៃទៀត នៅតាមភូមិ ឃុំទាំងអស់។

គ)- ប្រព័ន្ធបណ្តាញទូរគមនាគមន៍

- ប្រព័ន្ធបណ្តាញមេ បណ្តាញចែកចាយ និងស្ថានីយទូរគមនាគមន៍ នៅតាមក្រុង និងទីប្រជុំជនស្រុកទាំង១៣។

ឃ)- ការគ្រប់គ្រងសំណល់រឹង

- កំណត់យន្តការនិងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់គ្រប់គ្រងសំណល់រឹង
- កំណត់មធ្យោបាយសម្រាប់ការប្រមូលសំណល់រឹង និងទីលានបច្ចេកទេសគ្រប់គ្រង
- អនុវត្តគោលការណ៍ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ
- កំណត់គោលការណ៍ជំរុញលើកទឹកចិត្តវិស័យឯកជន ឱ្យចូលរួមក្នុងការវិនិយោគលើការគ្រប់គ្រងនិងកែច្នៃសំណល់រឹង។

ង)- ការគ្រប់គ្រងសំណល់រាវ

- កំណត់យន្តការនិងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់គ្រប់គ្រងសំណល់រាវ
- កែលម្អនិងពង្រីកបន្ថែមបណ្តាញលូបង្ហូរ និងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ឱ្យបានសមស្របតាមបទដ្ឋានបច្ចេកទេស
- កំណត់គោលការណ៍ជំរុញម្ចាស់រោងចក្រ សហគ្រាសឧស្សាហកម្ម សិប្បកម្ម អាជីវកម្ម សណ្ឋាគារ សេវាកម្មផ្សេងៗ និងលំនៅឋានគ្រប់ប្រភេទ ត្រូវរៀបចំអាងប្រព្រឹត្តិកម្មទឹកកខ្វក់ឱ្យបានសមស្របតាមបទដ្ឋានបច្ចេកទេស មុននឹងបង្ហូរចូលបណ្តាញលូសាធារណៈ

- កំណត់គោលការណ៍ជំរុញលើកទឹកចិត្តវិស័យឯកជន ឱ្យចូលរួមក្នុងការវិនិយោគលើការគ្រប់គ្រងនិងកែច្នៃសំណល់រាវ។

ច)- កំណត់តំបន់អភិវឌ្ឍឧស្សាហកម្មនៅតាមក្រុង និងស្រុក

- ក្រុងបាត់ដំបង ស្រុកសង្កែ និងស្រុកឯកភ្នំ ជាតំបន់ឧស្សាហកម្មចម្រុះ
- ស្រុករតនមណ្ឌល និងស្រុកកំរៀង ជាតំបន់ឧស្សាហកម្មកែច្នៃដំណាំចម្ការ
- ស្រុកបវេល និងស្រុកមោងឫស្សី ជាតំបន់ឧស្សាហកម្មកែច្នៃស្រូវ និងដំណាំចំការ
- ស្រុកថ្មគោល ជាតំបន់ឧស្សាហកម្មស្រូវ និងវេចខ្ចប់។

ឆ)- កំណត់ទីតាំងតំបន់សម្រាប់អភិវឌ្ឍធនធានរ៉ែ និងតំបន់សម្រាប់ការពារធនធានធម្មជាតិនិងធនធានវប្បធម៌។

### ៤.៣.៦- ការអភិវឌ្ឍទេសចរណ៍

តំបន់ទេសចរណ៍សំខាន់ៗដែលមានលក្ខណៈប្រវត្តិសាស្ត្រ វប្បធម៌ និងសំបូរដោយធនធានធម្មជាតិ គឺជាតំបន់ដែលមានសក្តានុពលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់សហគមន៍មូលដ្ឋាន ត្រូវធ្វើការអភិវឌ្ឍនិងអភិរក្ស គឺ៖

- តំបន់អភិវឌ្ឍទេសចរណ៍ និងសហគមន៍មូលដ្ឋាន
- តំបន់អភិរក្សប្រវត្តិសាស្ត្រ វប្បធម៌ និងធនធានធម្មជាតិ
- តំបន់ការពារប្រព័ន្ធជីវៈចម្រុះ និងអេកូទេសចរណ៍ មានចំនួនពីរកន្លែងគឺ៖ ១)តំបន់ភាគខាងលិចនៃខេត្ត ជាតំបន់ព្រៃការពារនិងតំបន់សម្បូរដោយព្រៃរបោះ និងព្រៃស្រោងដែលមានសណ្ឋានខុសៗគ្នា និង២)តំបន់ភាគខាងកើតនៃខេត្ត ជាតំបន់ទំនាបលិចទឹកជាប់បឹងទន្លេសាបដែលសម្បូរដោយព្រៃលិចទឹក គុម្ពោតឬវាលស្មៅលិចទឹក និងជាជម្រករបស់សត្វស្លាប និងមច្ឆជាតិគ្រប់ប្រភេទ។

## ៥- ផែនការសកម្មភាព

ផែនការសកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង តាមទិសដៅយុទ្ធសាស្ត្រដែលបានកំណត់ខាងលើ រួមមាន៖

### ៥.១- គម្រោងអាទិភាពក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ

ក)- ជំរុញអនុវត្តគម្រោងនានា តាមផែនការនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ លើវិស័យពាណិជ្ជកម្ម ការវិនិយោគ ផលិតផលកែច្នៃ ទេសចរណ៍ និងសេវាកម្មផ្សេងៗ។

ខ)- ជំរុញអនុវត្តតាមគម្រោងយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី ដែលខេត្តបាត់ដំបងដើរតួនាទីជា "មជ្ឈមណ្ឌលកំណើនអនុតំបន់" របស់អ័ក្សនៃការអភិវឌ្ឍសេដ្ឋកិច្ចខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ និងជាស្នូលនៃតំបន់ដែលមានបណ្តាញផ្លូវអាស៊ានឆ្លងកាត់។

### ៥.២- គម្រោងអាទិភាពក្នុងក្របខណ្ឌជាតិ

ក)- ជំរុញអនុវត្តគម្រោងអភិវឌ្ឍន៍នានា ស្របតាមអ័ក្ស "ភ្នំពេញ-បាត់ដំបង-ប៉ោយប៉ែត" តាមបណ្តោយផ្លូវជាតិលេខ៥។

ខ)- ជំរុញអនុវត្តគម្រោងអភិវឌ្ឍន៍នានា ស្របតាមអ័ក្សនៃតំបន់ជាប់បឹងទន្លេសាប។

គ)- ជំរុញអនុវត្តគម្រោងអភិវឌ្ឍន៍នានា ស្របតាមអ័ក្សនៃតំបន់ឆ្នេរតភ្ជាប់ពីប្រទេសថៃ។

ឃ)- ជំរុញអនុវត្តគម្រោងអភិវឌ្ឍន៍នានា ស្របតាមអ័ក្សនៃតំបន់ស្នូលជាយុទ្ធសាស្ត្រជួរមុខនៅតាមបណ្តោយព្រំដែនដីគោកកម្ពុជា-ថៃ។

### ៥.៣- គម្រោងអាទិភាពក្នុងក្របខណ្ឌខេត្ត

#### ៥.៣.១- ការអភិវឌ្ឍនគរូបនីយកម្មនិងលំនៅឋាន

ក)- ការអភិវឌ្ឍនគរូបនីយកម្ម

- ជំរុញការកំណត់ព្រំប្រទល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ
- ជំរុញការកសាងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនៅគ្រប់កម្រិត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ជំរុញការកសាងប្លង់លំអិតនគរូបនីយកម្ម សម្រាប់តំបន់នគរូបនីយកម្មទាំងបីកម្រិត គឺៈ ១) តំបន់នគរូបនីយកម្មកម្រិតខ្ពស់ ក្រុងបាត់ដំបង ២) តំបន់នគរូបនីយកម្មកម្រិតមធ្យម ទីប្រជុំជនស្រុកមោងឫស្សី ស្រុករតនមណ្ឌល ស្រុកថ្មគោល ស្រុកបវេល ស្រុកកំរៀង និងស្រុកសំពៅលូន និង ៣) តំបន់នគរូបនីយកម្មកម្រិតទាប ទីប្រជុំជនស្រុកឯកភ្នំ ស្រុកសង្កែ ស្រុករុក្ខគិរី ស្រុកគាស់ក្រឡ ស្រុកបាណន់ ស្រុកសំឡូត និងស្រុកភ្នំព្រឹក
- ចំពោះទីក្រុងដែលជាមជ្ឈមណ្ឌលរដ្ឋបាល ការស្នាក់នៅ មជ្ឈមណ្ឌលពាណិជ្ជកម្ម ការផលិតនិងកែច្នៃ និងសេវាកម្ម ត្រូវយកចិត្តទុកដាក់ចំពោះកំណើនប្រជាជន តម្រូវការលំនៅឋាន ការកកស្ទះចរាចរណ៍ និងតម្រូវការផ្សេងៗទៀតនៅក្នុងទីក្រុង
- ចំពោះតំបន់ជនបទ ត្រូវរក្សាលំនឹងនិងការអភិវឌ្ឍសក្តានុពលរបស់ខ្លួន ដើម្បីពង្រឹងឱ្យមានឯករាជ្យភាពជាតំបន់ស្នាក់នៅ តំបន់សម្បទានដីសង្គមកិច្ច និងតំបន់សម្បទានដីសេដ្ឋកិច្ច
- រៀបចំនិងពង្រីកលទ្ធភាពនៃការអភិវឌ្ឍទីក្រុង ដោយចាំបាច់ត្រូវមានបណ្តាញហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សារភ្ជាប់គ្នា

- ជំរុញការអនុវត្តបទប្បញ្ញត្តិនគរូបនីយកម្មក្នុងក្រុងនិងទីប្រជុំជន តាមមុខងារនៃតំបន់នគរូបនីយកម្មកម្រិតខ្ពស់ មធ្យម និងទាប
- ជំរុញការស្តារនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងក្រុងនិងទីប្រជុំជន និងការធ្វើសមាហរណកម្មនិងទំនាក់ទំនងតភ្ជាប់រវាងតំបន់នីមួយៗ
- រៀបចំអភិវឌ្ឍ និងអភិរក្សតំបន់លំហសាធារណៈ និងតំបន់ខ្សែក្រវាត់បៃតងក្នុងទីក្រុង ដើម្បីធានាបាននូវការរស់នៅប្រកបដោយគុណភាព សុវត្ថិភាព បរិស្ថានល្អ និងសោភណភាពធម្មជាតិ។

ខ)- ការអភិវឌ្ឍលំនៅឋាន

- ជំរុញការអភិវឌ្ឍលំនៅឋានតាមអ័ក្សនៃការអភិវឌ្ឍ ដែលតភ្ជាប់ពីតំបន់នគរូបនីយកម្មកម្រិតខ្ពស់ ទៅតំបន់នគរូបនីយកម្មកម្រិតមធ្យម និងទៅតំបន់នគរូបនីយកម្មកម្រិតទាប
- ជំរុញការអភិវឌ្ឍលំនៅឋានសមស្រប តាមតម្រូវការនិងលទ្ធភាពអាចទទួលបានសម្រាប់អ្នកមានប្រាក់ចំណូលទាប និងគ្រួសារក្រីក្រ ក្នុងទីក្រុង និងទីប្រជុំជន
- ជំរុញលើកទឹកចិត្តការវិនិយោគ និងអភិវឌ្ឍការសាងសង់លំនៅឋានថ្មីនៅក្នុងទីក្រុងទីប្រជុំជននិង/ឬតំបន់ជាយក្រុង ដើម្បីផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច ដោយកាត់បន្ថយការចំណាយលើការធ្វើដំណើរ កាត់បន្ថយចំណាកស្រុក និងកាត់បន្ថយគម្លាតពីតំបន់មួយទៅតំបន់មួយទៀត
- ជំរុញនិងលើកទឹកចិត្តការវិនិយោគសាងសង់លំនៅឋានថ្មី សម្រាប់បំពេញតម្រូវការនៃតំបន់សេដ្ឋកិច្ចពិសេស និងតំបន់អភិវឌ្ឍជួរមុខតាមព្រំដែន
- ជំរុញអនុវត្តគម្រោងអភិវឌ្ឍលំនៅឋានថ្មីក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច ក្នុងស្រុករុក្ខគីរី ស្រុកសំឡូត ស្រុករតនមណ្ឌល ស្រុកបវេល ស្រុកភ្នំព្រឹក និងស្រុកកំរៀង
- ជំរុញដោះស្រាយនិងគ្រប់គ្រងសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់។

### ៥.៣.២-ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន

ក)- ការអភិវឌ្ឍបណ្តាញផ្លូវថ្នល់

- ស្តារនិងអភិវឌ្ឍផ្លូវខេត្តជាអាទិភាពចំនួន១៤ខ្សែ ដែលតភ្ជាប់ទៅកាន់តំបន់នគរូបនីយកម្មក្រុង ទីប្រជុំជន និងតំបន់លំនៅឋានជនបទ
- ជំរុញការស្តារនិងកែលម្អបណ្តាញមានស្រាប់ ឬលើកគម្រោងស្នើសុំសាងសង់ថ្មី ដែលជាអ័ក្សតភ្ជាប់រវាងស្នូលអភិវឌ្ឍនគរូបនីយកម្មទាំងអស់

- ជំរុញការស្តារនិងកែលម្អបណ្តាញមានស្រាប់ ឬលើកគម្រោងស្នើសុំសាងសង់ថ្មី ដែលជាអ័ក្សតភ្ជាប់រវាងស្នូលអភិវឌ្ឍកសិកម្ម និងឧស្សាហកម្មក្នុងខេត្តនិងភ្ជាប់ទៅកាន់តំបន់ជុំវិញ។

ខ)- ការអភិវឌ្ឍបណ្តាញផ្លូវអយស្ម័យយាន

- អភិវឌ្ឍបណ្តាញផ្លូវអយស្ម័យយានក្នុងខេត្ត និងស្ថានីយរថភ្លើងក្រុងបាត់ដំបង។

គ)- បណ្តាញផ្លូវទឹកនិងកំពង់ផែ

- ជំរុញនិងបង្កើនសកម្មភាពដឹកជញ្ជូនតាមផ្លូវទឹកនៃស្ទឹងសង្កែ ដែលជាបណ្តាញផ្លូវទឹកសំខាន់នៅក្នុងខេត្ត និងតភ្ជាប់ទៅបឹងទន្លេសាប
- ស្តារនិងកែលម្អកំពង់ផែទី១ស្ថិតនៅក្នុងក្រុងបាត់ដំបង សម្រាប់អ្នកទេសចរធ្វើដំណើរទៅមកក្នុងខេត្តបាត់ដំបងនិងទៅកាន់ខេត្តសៀមរាប
- ស្តារនិងកែលម្អកំពង់ផែទី២ស្ថិតនៅទល់មុខផ្សារឃុំព្រែកនរិន្ទ ស្រុកឯកភ្នំសម្រាប់ការដឹកជញ្ជូនទំនិញផ្សេងៗ និងការចូលចតរបស់កាណូតធំៗនៅរដូវវស្សា។

ឃ)- បណ្តាញផ្លូវអាកាស

- ស្តារនិងកែលម្អអាកាសយានដ្ឋានបច្ចុប្បន្ន
- សិក្សានិងកំណត់ទីតាំងថ្មីសមស្របសម្រាប់សាងសង់អាកាសយានដ្ឋានថ្មី។

### ៥.៣.៣- ការគ្រប់គ្រងទីជម្រាលប្រកបដោយចីរភាព

ក)- ការគ្រប់គ្រងដីព្រៃ

- ជំរុញការធ្វើចំណាត់ថ្នាក់និងការចុះបញ្ជីដីព្រៃគ្រប់ប្រភេទ
- ពង្រឹងការគ្រប់គ្រងដែនជម្រកសត្វព្រៃរនាមដូនសំ ដែនជម្រកសត្វព្រៃភ្នំសំកុស និងតំបន់ប្រើប្រាស់ចម្រុះសំឡូត
- កំណត់ព្រំប្រទល់តំបន់ឱ្យបានច្បាស់លាស់ ដូចជាតំបន់ស្នូល(ព្រែកទាល់) តំបន់អភិរក្ស តំបន់ប្រើប្រាស់ប្រកបដោយចីរភាព និងតំបន់សហគមន៍។

ខ)- ការគ្រប់គ្រងសហគមន៍ព្រៃឈើ

- ពង្រឹងការគ្រប់គ្រងតំបន់សហគមន៍ព្រៃឈើដែលបានកំណត់ចំនួន៥១ទីតាំង ដោយធ្វើការចុះកិច្ចព្រមព្រៀងដើម្បីការពារនិងផ្តល់អនុផលព្រៃឈើដល់សហគមន៍ទាំងនោះ ព្រមទាំងជំរុញបង្កើតតំបន់សហគមន៍ព្រៃឈើចំនួន៣៣ទីតាំងបន្ថែមទៀត។

គ)- ការគ្រប់គ្រងតំបន់វាលទំនាបជាប់បឹងទន្លេសាបនិងសហគមន៍នេសាទ

- ពង្រឹងការគ្រប់គ្រងតំបន់សហគមន៍នេសាទដែលបានកំណត់ចំនួន៤៦កន្លែង ដោយធ្វើការចុះកិច្ចព្រមព្រៀង ដើម្បីការពារនិងផ្តល់ផលនេសាទដល់សហគមន៍ ព្រមទាំងពង្រឹងការគ្រប់គ្រងលើការអភិវឌ្ឍសាងសង់គ្រប់ប្រភេទក្នុងតំបន់ទាំងនេះ។

ឃ)- ការការពារទីជម្រាលជាប់ខ្សែទឹកធម្មជាតិ

- ពង្រឹងការគ្រប់គ្រងការប្រើប្រាស់ដីកសិកម្ម នៅតាមទីជម្រាលជាប់ខ្សែទឹកធម្មជាតិ
- ហាមឃាត់ការប្រើប្រាស់ជាតិគីមីពុល ដែលអាចប៉ះពាល់ដល់បរិស្ថាន និងសុខភាពមនុស្ស សត្វ
- ជំរុញការការពារព្រៃឈើនិងលើកទឹកចិត្តការដាំដើមឈើនៅតាមទីជម្រាល
- ការពារនិងទប់ស្កាត់ការហូរច្រោះឬបាក់ដីនៅតាមទីជម្រាល។

## ៥.៣.៤-ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រនិងកសិកម្ម

ក)- ការស្តារប្រព័ន្ធធារាសាស្ត្រសម្រាប់ប្រពលវប្បកម្មដំណាំស្រូវ

- ជំរុញការស្តារនិងពង្រីកបន្ថែមប្រព័ន្ធប្រឡាយមេនិងអាងស្តុកទឹកធំៗចំនួន៦កន្លែង ដែលមានសក្តានុពលគ្របដណ្តប់តំបន់ផលិតកម្មស្រូវនៅទូទាំងខេត្ត
- ជំរុញការធ្វើប្រពលវប្បកម្មដំណាំស្រូវតាមរយៈបច្ចេកទេសទំនើប ដើម្បីបង្កើនទិន្នផលស្រូវខ្ពស់។

ខ)- ការថែរក្សាសក្តានុពលដីកសិកម្មសម្រាប់ការអភិវឌ្ឍរយៈពេលវែង

- ជំរុញថែរក្សានិងការពារសក្តានុពលនៃប្រព័ន្ធជីវៈចម្រុះរបស់ដីនិងការកែលម្អគុណភាពដីឡើងវិញទាំងផ្នែកគីមីសាស្ត្រនិងរូបសាស្ត្រ
- ជំរុញការគ្រប់គ្រងលើសណ្ឋានដីនិងចរន្តទឹកហូរ តាមរយៈបច្ចេកទេសវិស្វកម្ម។

គ)- ការលើកស្ទួយផលិតផលកសិកម្មតាមតំបន់

- ជំរុញការកែច្នៃផលិតផលកសិកម្មចម្រុះប្រចាំតំបន់
- កែលម្អចង្វាក់ផលិតកម្មកសិកម្មមូលដ្ឋាន ដើម្បីបង្កើនបរិមាណនិងគុណភាព
- លើកកម្ពស់ផលិតផលផ្លាកសម្គាល់ភូមិសាស្ត្រទំនិញ "ផលិតផលខេត្តបាត់ដំបង" តាមរយៈការផ្សព្វផ្សាយ និងការធ្វើទីផ្សារលក់។

ឃ)- ការអភិវឌ្ឍការចិញ្ចឹមសត្វ

- នៅក្នុងស្រុកថ្មគោល ស្រុកបវេល ស្រុកមោងឬស្សី ស្រុកសង្កែ ស្រុកបាណន់ និងស្រុករតនមណ្ឌល ត្រូវលើកកម្ពស់ការចិញ្ចឹមសត្វជ្រូក មាន់ ទា សម្រាប់ធ្វើជាអាហារ
- នៅក្នុងស្រុកគាស់ក្រឡ ស្រុកមោងឬស្សី និងស្រុកសំឡូត ត្រូវលើកកម្ពស់ការចិញ្ចឹមសត្វគោ ក្របី សម្រាប់បម្រើដល់កសិកម្ម និងធ្វើជាអាហារ។

## ៥.៣.៥-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសនិងឧស្សាហកម្ម

ក)- ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស

- ជំរុញការសាងសង់ទំនប់វារីអគ្គិសនីបាត់ដំបង១ និងទំនប់វារីអគ្គិសនីបាត់ដំបង២ ដែលបានកំណត់រួច

- ជំរុញការកសាងនិងស្តារបណ្តាញផ្គត់ផ្គង់ចរន្តអគ្គិសនី ទឹកស្អាត ទូរគមនាគមន៍ ព័ត៌មាន និងទំនាក់ទំនងសេវាកម្មសុខភាពសាធារណៈក្នុងតំបន់ក្រុង និងជនបទ។

ខ)- ការអភិវឌ្ឍបណ្តាញចែកចាយថាមពលអគ្គិសនីមានស្រាប់

- ជំរុញការអភិវឌ្ឍបណ្តាញចែកចាយថាមពលអគ្គិសនីដែលមានស្រាប់ឱ្យបានគ្រប់ទីកន្លែង។

គ)- ការអភិវឌ្ឍតំបន់ឧស្សាហកម្ម

- ជំរុញបង្កើតតំបន់ឧស្សាហកម្មចម្រុះ នៅក្រុងបាត់ដំបង ស្រុកសង្កែ និងស្រុកឯកភ្នំ
- ជំរុញបង្កើតតំបន់ឧស្សាហកម្មកែច្នៃដំណាំចម្ការ នៅស្រុករតនមណ្ឌលនិងស្រុកកំរៀង
- ជំរុញបង្កើតតំបន់ឧស្សាហកម្មកែច្នៃស្រូវនិងដំណាំចម្ការ នៅស្រុកបវេលនិងស្រុកមោងឫស្សី
- ជំរុញបង្កើតតំបន់ឧស្សាហកម្មស្រូវនិងវេចខ្ចប់ នៅស្រុកថ្មគោល។

ឃ)- ការធ្វើអាជីវកម្មលើសំណល់រឹង រាវ

- ជំរុញភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងការធ្វើអាជីវកម្មលើសំណល់រឹងរាវ
- ជំរុញអនុវត្តគោលការណ៍ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ
- ជំរុញអប់រំនិងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជន ដើម្បីធ្វើការផ្លាស់ប្តូរឥរិយាបថលើការទុកដាក់ និងសម្អាតសំរាម។

### ៥.៣.៦-ការអភិវឌ្ឍទេសចរណ៍

ក)- ការអភិវឌ្ឍតំបន់ទេសចរណ៍និងសហគមន៍មូលដ្ឋាន

- លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានអំពីតំបន់ទេសចរណ៍ទាំង៣៩ទីតាំង ដែលបានកំណត់ និងតំបន់ទេសចរណ៍ដទៃទៀត ដើម្បីទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិ និងអ្នកសិក្សាស្រាវជ្រាវនានា
- កសាងសមត្ថភាព លើកកម្ពស់ការយល់ដឹង និងពង្រឹងគុណភាពនៃការផ្គត់ផ្គង់សេវាកម្មទេសចរណ៍របស់ប្រជាជនក្នុងសហគមន៍មូលដ្ឋាន។

ខ)- ការអភិរក្សតំបន់ប្រវត្តិសាស្ត្រ វប្បធម៌ និងធនធានធម្មជាតិ

- ពង្រឹងការកសាងបទដ្ឋានគតិយុត្តតាមវិស័យពាក់ព័ន្ធ
- ពង្រឹងការគ្រប់គ្រងនិងការពារតាមរយៈវិធានការជាក់លាក់ ដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន
- បង្កើនសកម្មភាពការងារអភិរក្សនៅតំបន់ទាំងនេះ ដោយមានការចូលរួមពីអង្គការជាតិនិងអន្តរជាតិ ដៃគូអភិវឌ្ឍ និងអ្នកជំនាញគ្រប់ប្រភេទ។

គ)- ការការពារប្រព័ន្ធជីវៈចម្រុះនិងការលើកស្ទួយវិស័យអេកូទេសចរណ៍

- កំណត់តំបន់ការពារប្រព័ន្ធជីវៈចម្រុះ ក្នុងតំបន់ព្រៃរបោះនិងព្រៃស្រោងនៅភាគខាងលិចនៃខេត្ត
- កំណត់តំបន់ការពារប្រព័ន្ធជីវៈចម្រុះ ក្នុងតំបន់វាលទំនាបលិចទឹកជាប់បឹងទន្លេសាប
- ជំរុញលើកស្ទួយវិស័យអេកូទេសចរណ៍ក្នុងតំបន់ទាំងនេះ
- ពង្រឹងការគ្រប់គ្រង តាមរយៈការចូលរួមរបស់សហគមន៍មូលដ្ឋាន។

### ៥.៤- ការផ្សព្វផ្សាយ

រដ្ឋបាលខេត្តបាត់ដំបង ត្រូវធ្វើការផ្សព្វផ្សាយនិងបញ្ជ្រាបផែនការរៀបចំដែនដីនេះ ឱ្យបានទូលំទូលាយតាមគ្រប់រូបភាពដល់គ្រប់ស្ថាប័ន អង្គភាពពាក់ព័ន្ធ ក្រុមអ្នកជំនាញ វិនិយោគិន និងប្រជាពលរដ្ឋទូទៅ ឱ្យទទួលបាននូវព័ត៌មានស្តីពីផែនការនេះ ដើម្បីសហការអនុវត្តឱ្យមានប្រសិទ្ធភាព។

## ៦-ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុ សម្រាប់ការអនុវត្តផែនការរៀបចំដែនដីខេត្តបាត់ដំបង បានមកពីៈ

- ថវិកាជាតិ
- ថវិកាឯកជន
- ថវិកាភាពជាដៃគូរវាងរដ្ឋនិងឯកជន
- ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៧-ការត្រួតពិនិត្យនិងវាយតម្លៃ

### ៧.១- យន្តការ

យន្តការនៅថ្នាក់ជាតិសម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការរៀបចំដែនដីខេត្តបាត់ដំបងរួមមានៈ

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ។

យន្តការនៅថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃផែនការរៀបចំដែនដីខេត្តបាត់ដំបងរួមមានៈ

- រដ្ឋបាលខេត្តបាត់ដំបង
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តបាត់ដំបង
- មន្ទីរ អង្គភាពពាក់ព័ន្ធរបស់ខេត្ត និងអាជ្ញាធរក្រុង ស្រុក ឃុំ សង្កាត់ ជាសមាជិក។

### ៧.២-ក្របខណ្ឌច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរៀបចំដែនដីខេត្តបាត់ដំបងត្រូវផ្អែកលើក្របខណ្ឌច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត មានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គោលនយោបាយដីធ្លី គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋាន គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សេចក្តីសម្រេចស្តីពីការរៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

### ៧.៣-គោលការណ៍ នីតិវិធី និងភារកិច្ច

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តបាត់ដំបង ដែលមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ជាសមាជិកអចិន្ត្រៃយ៍ ត្រូវអនុវត្តតាមគោលការណ៍ នីតិវិធី និងភារកិច្ច ដូចខាងក្រោម៖

- កំណត់សូចនករនៃហេតុប៉ះពាល់សង្គមនិងបរិស្ថានសម្រាប់ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនិងគុណភាពនៃការអនុវត្តផែនការរៀបចំដែនដីនេះ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាព
- ទទួលខុសត្រូវរៀបចំផែនការសកម្មភាពលម្អិតនៃគម្រោងអភិវឌ្ឍន៍នានា សម្រាប់ការអនុវត្តផែនការរៀបចំដែនដីនេះ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព វិស័យឯកជន ដៃគូអភិវឌ្ឍ និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើត្រូវកំណត់នូវគោលបំណង គោលដៅ សកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនករសំខាន់ៗសម្រាប់ការត្រួតពិនិត្យនិងការវាយតម្លៃ ព្រមទាំងត្រូវមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំ កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់

- ត្រូវធ្វើបច្ចុប្បន្នភាពផែនការរៀបចំដែនដីខេត្តបាត់ដំបងក្នុងរយៈពេល៥ឆ្នាំម្តង ស្របតាមគោលការណ៍និងនីតិវិធីជាធរមាន រួចស្នើសុំការឯកភាពពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីស្នើសុំការសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការពីរាជរដ្ឋាភិបាល
- ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យនិងការវាយតម្លៃលើការអនុវត្តផែនការរៀបចំដែនដីនេះ ជូនក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**៨-សេចក្តីសន្និដ្ឋាន**

ផ្អែកលើលទ្ធផលនៃការវិភាគបែបវិទ្យាសាស្ត្រលើសក្តានុពលនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងបរិស្ថាន ផែនការរៀបចំដែនដីខេត្តបាត់ដំបងបានកំណត់នូវចក្ខុវិស័យឆ្នាំ២០៣០ ប្រកបដោយភាពច្បាស់លាស់និងមានប្រសិទ្ធភាពអាចអនុវត្តបាន ដោយបានកំណត់នូវយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍និងផែនការសកម្មភាពនៃគម្រោងអាទិភាពនានាដែលនឹងត្រូវធ្វើឱ្យបានសម្រេចក្នុងរយៈពេលខ្លី មធ្យម និងវែង ចាប់ពីពេលនេះរហូតដល់ឆ្នាំ២០៣០ ស្របតាមលក្ខណៈពិសេសនៃភូមិសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ធម្មជាតិ ប្រវត្តិសាស្ត្រ និងវប្បធម៌។

ផែនការនេះ គឺជាឧបករណ៍គតិយុត្តដ៏សំខាន់សម្រាប់តម្រង់ទិសផែនការអភិវឌ្ឍន៍នៅគ្រប់កម្រិតនៃតំបន់នីមួយៗក្នុងខេត្ត និងសម្របសម្រួលជាមួយផែនការដទៃទៀត សំដៅធានាការគ្រប់គ្រង ការពារ បែងចែក និងប្រើប្រាស់ដី បរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព។

ដូចនេះ ការដាក់ឱ្យអនុវត្តនូវផែនការរៀបចំដែនដីខេត្តបាត់ដំបង គឺជាការចាំបាច់បំផុតសម្រាប់តម្រង់ទិសការអភិវឌ្ឍនិងអភិរក្សលើផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាននៃដែនដីខេត្តទាំងមូលឱ្យក្លាយជា ***"តំបន់ស្នូលសេដ្ឋកិច្ចភាគពាយ័ព្យនៃប្រទេសកម្ពុជា"*** និងផ្តល់នូវផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដល់តំបន់ជុំវិញក្នុងក្របខណ្ឌជាតិ ក្របខណ្ឌតំបន់ និងក្របខណ្ឌអន្តរជាតិ រួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជាទាំងមូល ស្របតាមការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល គឺការធ្វើឱ្យកម្ពុជាក្លាយជាប្រទេសដែល "មានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០"៕

## សទ្ទានុក្រម

**ផែនការរៀបចំដែនដីថ្នាក់ជាតិ តាមតំបន់ ថ្នាក់ខេត្តៈ**

ជាផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសការប្រើប្រាស់ដី និងការអភិវឌ្ឍផ្នែករូបវន្ត ដោយផ្អែកលើសក្តានុពលនៃភូមិសាស្ត្រ និងតំបន់នីមួយៗ ក្នុងក្របខណ្ឌខេត្ត ថ្នាក់ជាតិ តាមតំបន់ និងថ្នាក់ខេត្ត។

**ប្លង់គោលប្រើប្រាស់ដីថ្នាក់រាជធានី ថ្នាក់ក្រុង ថ្នាក់ស្រុក ថ្នាក់ខណ្ឌៈ**

ជាផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្ររួមសម្រាប់ការអភិវឌ្ឍផ្នែករូបវន្ត និងកំណត់អំពីប្រភេទដី ព្រមទាំងបង្ហាញអំពីហេដ្ឋារចនាសម្ព័ន្ធនិងគមនាគមន៍សំខាន់ៗ និងការធ្វើសមាហរណកម្មក្របខណ្ឌថ្នាក់រាជធានី ថ្នាក់ក្រុង ថ្នាក់ស្រុក និងថ្នាក់ខណ្ឌ ទៅថ្នាក់ជាតិនិងតាមតំបន់។

**ផែនការប្រើប្រាស់ដីថ្នាក់រាជធានី ថ្នាក់ក្រុងៈ**

ជាផែនការលម្អិតចេញពីប្លង់គោល ដែលកំណត់អំពីប្រភេទនៃការប្រើប្រាស់ដីនៅតំបន់នីមួយៗ កំណត់អំពីបទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍដី និងលទ្ធភាពនៃការសាងសង់ក្នុងតំបន់នីមួយៗ ព្រមទាំងបង្ហាញអំពីហេដ្ឋារចនាសម្ព័ន្ធ និងការធ្វើសមាហរណកម្មទៅថ្នាក់ជាតិនិងតាមតំបន់។

**ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ៈ**

ជាផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជន ដោយប៉ាន់ប្រមាណពីសក្តានុពលដីនិងធនធានទឹក លទ្ធភាពផ្សេងៗក្នុងការប្រើប្រាស់ដី ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គម ដើម្បីធ្វើការជ្រើសរើសនូវជម្រើសសមស្របក្នុងការប្រើប្រាស់ដី។

**ការត្រួតពិនិត្យការអភិវឌ្ឍៈ**

ការត្រួតពិនិត្យការអនុវត្ត ស្របតាមប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងស្របតាមបទប្បញ្ញត្តិជាធរមាន។

**តំបន់ស្នូលនៃការអភិវឌ្ឍៈ**

តំបន់ដែលមានសក្តានុពលខ្ពស់ ឬតំបន់ដែលមានការអភិវឌ្ឍខ្ពស់សម្រាប់គាំទ្រដល់តំបន់ដែលមានសក្តានុពលទាប។

**អ័ក្សនៃការអភិវឌ្ឍៈ**

បណ្តាញផ្លូវគមនាគមន៍ ឬច្រករបៀងតភ្ជាប់ពីតំបន់អភិវឌ្ឍន៍មួយទៅតំបន់អភិវឌ្ឍន៍មួយទៀត ដែលអាចឱ្យតំបន់ជាប់ជិតខាងតាមអ័ក្សទាញយកប្រយោជន៍ពីការអភិវឌ្ឍតាមអ័ក្សនេះបាន។

**ប៉ូលអភិវឌ្ឍៈ**

តំបន់ដែលមានសក្តានុពលខ្ពស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។

## ឯកសារឧបសម្ព័ន្ធ

- របាយការណ៍បច្ចេកទេស
- ផែនទីយុទ្ធសាស្ត្រគ្រប់គ្រងទីជម្រាលប្រកបដោយចីរភាព
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធអគ្គិសនីនិងឧស្សាហកម្ម
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍នគរូបនីយកម្មនិងលំនៅឋាន
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍
- ផែនទីរួមយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍ថ្នាក់ខេត្ត។

ផែនការរៀបចំដែនដីខេត្តបាត់ដំបង ចក្ខុវិស័យឆ្នាំ ២០៣០
Spatial Plan of Battambang Province, Vision 2030







ផែនទីយុទ្ធសាស្ត្រគ្រប់គ្រងដីថ្នាលប្រកបដោយចីរភាព

## ផែនការរៀបចំដែនដីខេត្តបាត់ដំបង ចក្ខុវិស័យឆ្នាំ ២០៣០
## Spatial Plan of Battambang Province, Vision 2030







ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធតាមសាស្ត្រ

# ផែនការរៀបចំដែនដីខេត្តបាត់ដំបង ចក្ខុវិស័យឆ្នាំ ២០៣០
Spatial Plan of Battambang Province, Vision 2030




ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

0 5 10 20 Km

# ផែនការរៀបចំដែនដីខេត្តបាត់ដំបង ចក្ខុវិស័យឆ្នាំ ២០៣០
## Spatial Plan of Battambang Province, Vision 2030







ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធអគ្គិសនី និងឧស្សាហកម្ម

# ផែនការរៀបចំដែនដីខេត្តបាត់ដំបង ចក្ខុវិស័យឆ្នាំ ២០៣០
## Spatial Plan of Battambang Province, Vision 2030




ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍នគរូបនីយកម្ម និងលំនៅឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

មាត្រដ្ឋានផែនទី

0 5 10 20 Km

ផែនទីលេខ ៥

# ផែនការរៀបចំដែនដីខេត្តបាត់ដំបង ចក្ខុវិស័យឆ្នាំ ២០៣០
## Spatial Plan of Battambang Province, Vision 2030




ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

0 10 20 40 Km

ផែនទីលេខ ៦

ព្រំប្រទល់ខេត្ត
ផ្លូវជាតិ
ផ្លូវខេត្ត
ផ្លូវវាងក្រុង
ផ្លូវដែក

ប្រាសាទ
រមណីយដ្ឋានធម្មជាតិ
សារមន្ទីរ
វត្ត

# ផែនការរៀបចំដែនដីខេត្តបាត់ដំបង ចក្ខុវិស័យឆ្នាំ ២០៣០
## Spatial Plan of Battambang Province, Vision 2030



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ខេត្ត

0 5 10 20 Km

# ផែនទី ផែនការរៀបចំដែនដីខេត្តបាត់ដំបង ចក្ខុវិស័យឆ្នាំ២០៣០

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ............ចុះថ្ងៃ............ខែ............ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី...១៣...ខែ............ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ




មាត្រដ្ឋានផែនទី

0 5 10 20 30

គីឡូម៉ែត្រ

សន្លឹកទី : ០១

ជា សុផារ៉ា

ងួន រតនៈ